# Promoting Climate-Resilient Livelihoods in Rice-Based Communities in the Tonle Sap Region (PCRL)


© GDA/MAFF

The Royal Government of Cambodia has received grant financing from the Global Environment Facility (GEF) through the Food and Agriculture Organization of the United Nations (FAO) to implement the five-year project (2022–2027) that has the objective is to reduce the climate vulnerability of the rice-based communities and increase their resilience to climate change through an ecosystem-based, market-driven approach. The PCRL Project is implemented jointly by the General Directorate of Agriculture (GDA) of the Ministry of Agriculture, Forestry and Fisheries, and the General Directorate of Local Community (GDLC) of the Ministry of Environment.


© Landesacambodia

## Root Causes

- Low farm incomes and poverty, high production costs with limited access to credit and extensive system.
- Fragmented supply chains and insufficient access to technologies.
- Low levels of investment in infrastructure and irrigation/ water management, less farm diversification, and limited access to land.

## Threats

- Increased climate variability, changes in precipitation and increased of extreme weather events such as droughts, floods and extreme temperatures.
- Increased pests and diseases, potentially leading to reduced crop yields and livestock.
- Affecting food security and nutrition.
- Reduced household incomes and increased poverty.

## Barriers to Adaptation

- Inadequate enabling environment for climate change adaptation in the agricultural sector, particularly for rice production.
- Current agricultural networks are narrowly suited to conventional production practices that contribute to high vulnerability to climate change.
- The conventional agricultural value chains reinforce climate vulnerabilities.
- Insufficient knowledge management systems.

**Co-implemented by:**

**With the technical support of:**

Food and Agriculture Organization of the United Nations

**Funded by:**

gef

# Project Components

**Component 1** Improving the enabling environment for CCA in the rice and related priority sectors through integrated policies and planning.

Outcome 1.1 Strengthened national and sub-national climate change adaptation policies, planning frameworks, and governance.

**Component 2** Screening resilient production systems in rice-based communities for improved livelihoods.

Outcome 2.1 Increased resilience and adaptive capacities of production systems and the natural resource base

**Component 3** Scaling up adaptation technologies and practices in selected AVCs through partnerships, markets, and investments.

Outcome 3.1 Scaling of adaptation innovations, technologies and new markets, and scaling up agribusinesses, employment, and empowerment at community level.

**Component 4** Building effective knowledge management, innovations, and monitoring & evaluation systems.

Outcome 4.1 More effective knowledge management and assessment of adaptation innovations.



© PCRL/PMU

## Target Provinces

The PCRL project works in five target provinces around the Tonle Sap Lake i.e. Pursat, Battambang, Banteay Meanchey, Siem Reap, and Kampong Thom, covering a total of 40 communes in 24 districts, where are the major rainfed rice-growing region ,and vulnerable communities that have little adaptability to climate change.


©aquaexpeditions

## Expected Results

- 170,200 people with increased adaptive capacity
- 67,309 ha of agricultural landscapes under climate-resilient management.
- Ecosystem services are maintained or enhanced.
- Climate-resilient development is increased in rice-producing communities around Tonle Sap.

## Long-term Outcomes

- Increased productivity and quality of stallholder in agricultural products
- Increased incomes, household economic resilience, nutrition and food security.
- Reduced land degradation & GHG emissions, increased biodiversity, and resilient ecosystems.

**Co-implemented by:**

**With the technical support of:**

Food and Agriculture Organization of the United Nations

**Funded by:**

gef

# គម្រោងការលើកកម្ពស់ជីវភាពធន់នឹងអាកាសធាតុនៃសហគមន៍ផលិតស្រូវនៅតំបន់ទន្លេសាប


© GDA/MAFF

រាជរដ្ឋាភិបាលកម្ពុជា បានទទួលហិរញ្ញប្បទានឥតសំណងពីមូលនិធិបរិស្ថានសកល (GEF) តាមរយៈអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) សម្រាប់អនុវត្តគម្រោងដែលមានរយៈពេលប្រាំឆ្នាំ (២០២២-២០២៧) និងអនុវត្តរួមគ្នាដោយអគ្គនាយកដ្ឋានកសិកម្ម (GDA) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន (GDLC) នៃក្រសួងបរិស្ថាន។ គោលបំណងរួមរបស់គម្រោង គឺដើម្បីកាត់បន្ថយភាពងាយរងគ្រោះដោយសារអាកាសធាតុរបស់សហគមន៍ដាំស្រូវ និងបង្កើនភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុរបស់ប្រជាសហគមន៍ដាំស្រូវនៅតំបន់បឹងទន្លេសាប តាមរយៈការអនុវត្តវិធីសាស្ត្រផលិតកម្មផ្អែកលើប្រព័ន្ធអេកូឡូស៊ី និងជំរុញចរន្តទីផ្សារ។


© Landesacambodia

## ឫសគល់នៃគម្រោង

- ភាពក្រីក្រមានទំនាក់ទំនងនឹងប្រាក់ចំណូលទាបពីផលិតកម្ម បណ្តាលមកពីថ្លៃដើមខ្ពស់ លទ្ធភាពឥណទានទាប និងការដាំដុះជាយថាផល។
- ខ្សែចង្វាក់ផ្គត់ផ្គង់នៅបែកខ្ញែក ខណៈការប្រើប្រាស់បច្ចេកវិទ្យានៅមិនទាន់មានភាពល្អប្រសើរ។
- ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធធារាសាស្ត្រមិនទាន់គ្រប់គ្រាប់ ការធ្វើពិពិធកម្មដំណាំទាប ព្រមទាំងដីសម្រាប់ប្រើប្រាស់លើផលិតកម្មនៅមានកម្រិត។
- ការកើនឡើងនៃការប្រែប្រួលអាកាសធាតុ ការផ្លាស់ប្តូរនៃរបបទឹកភ្លៀង ព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរកើតឡើងញឹកញាប់ ដូចជាគ្រោះរាំងស្ងួត គ្រោះទឹកជំនន់ និងសីតុណ្ហភាពក្តៅខ្លាំង។
- ការកើនឡើងនៃពពួកសត្វល្អិត និងជំងឺ នាំឱ្យខាតបង់ទិន្នផលកសិកម្ម។
- ប៉ះពាល់ដល់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។
- ខាតបង់ប្រាក់ចំណូលគ្រួសារ និងនាំឱ្យមានភាពក្រីក្រ។

## ឧបសគ្គចំពោះការបន្សាំ

- ការសម្រួលបរិយាកាសនៅមិនទាន់គ្រប់គ្រាន់សម្រាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យ កសិកម្ម ជាពិសេសផលិតកម្មស្រូវ។
- បណ្តាញកសិកម្មបច្ចុប្បន្ន មានលក្ខណៈគាំទ្រចំពោះផលិតកម្មកសិកម្មតាមទម្លាប់របស់កសិករ ដែលជាកត្តារួមចំណែកដល់ភាពងាយរងគ្រោះខ្ពស់ទៅនឹងការប្រែប្រួលអាកាសធាតុ។
- ខ្សែចង្វាក់តម្លៃកសិកម្ម បន្ថែមបន្ទុកលើភាពងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ។
- ប្រព័ន្ធគ្រប់គ្រងចំណេះដឹងនៅមិនទាន់មានភាពពេញលេញ។

Co-implemented by:

With the technical support of:

Food and Agriculture Organization of the United Nations

Funded by:

gef

# សមាសភាគគម្រោង

**សមាសភាគទី ១៖** ការកែលម្អបរិយាកាសអំណោយផលសម្រាប់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យស្រូវអង្ករ និងវិស័យអាទិភាពពាក់ព័ន្ធ តាមរយៈការធ្វើគោលនយោបាយ និងផែនការរួមគ្នា។

លទ្ធផលរូបវន្ត ១.១៖ គោលនយោបាយបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងក្របខ័ណ្ឌផែនការ និងអភិបាលកិច្ចទទួលបានការពង្រឹងអោយកាន់តែរឹងមាំ។

**សមាសភាគទី ២៖** ការគាំទ្រប្រព័ន្ធផលិតកម្មធន់នឹងអាកាសធាតុនៅតាមសហគមន៍ផលិតស្រូវ ដើម្បីឱ្យជីវភាពរស់នៅបានប្រសើរឡើង។

លទ្ធផលរូបវន្ត ២.១៖ សមត្ថភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុនៃប្រព័ន្ធផលិតកម្ម និងធនធានធម្មជាតិនៅមូលដ្ឋាន មានភាពធន់កាន់តែប្រសើរ។

**សមាសភាគទី ៣៖** ការពង្រីកវិសាលភាពបច្ចេកវិទ្យាបន្សាំ និងការអនុវត្តនៅក្នុងខ្សែច្រវាក់តម្លៃដែលបានជ្រើសរើស តាមរយៈភាពជាដៃគូរទីផ្សារ និងការវិនិយោគ។

លទ្ធផលរូបវន្ត ៣.១៖ ការពង្រឹងវិសាលភាពនៃការច្នៃប្រឌិតថ្មីក្នុងការបន្សាំ បច្ចេកវិទ្យា និងទីផ្សារថ្មីៗ ព្រមទាំងការពង្រីកអាជីវកម្មកសិកម្ម ឱកាសការងារ និងការពង្រឹងសិទ្ធិអំណាចនៅកម្រិតសហគមន៍។

**សមាសភាគទី ៤៖** ការកសាងការគ្រប់គ្រងចំណេះដឹង នវានុវត្តន៍ និងប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃប្រកបដោយប្រសិទ្ធភាព។

លទ្ធផលរូបវន្ត ៤.១៖ ការគ្រប់គ្រងចំណេះដឹង និងការវាយតម្លៃនវានុវត្តន៍នានាក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ កាន់តែមានប្រសិទ្ធិភាពឡើង។




© PCRL/PMU

## តំបន់គោលដៅ

គម្រោង PCRL អនុវត្តក្នុងខេត្តគោលដៅចំនួនប្រាំនៅជុំវិញបឹងទន្លេសាប ពោលគឺខេត្តពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងកំពង់ធំ ដែលជាតំបន់ដាំដុះស្រូវដ៏សំខាន់ដែលមានភ្លៀងធ្លាក់ច្រើន ប៉ុន្តែលទ្ធភាពប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រមានកម្រិត និងជាទីដែលសហគមន៍ងាយរងគ្រោះភាគច្រើនមានលទ្ធភាពបន្សាំតិចតួចទៅនឹងការប្រែប្រួលអាកាសធាតុ។



©aquaexpeditions

## លទ្ធផលរំពឹងទុក

- បង្កើនភាពធន់ និងសមត្ថភាពបន្សាំដល់កសិករ ១៧០,២០០ នាក់
- ផ្ទៃដីកសិកម្មដែលធន់នឹងអាកាសធាតុ ៦៧,៣០៩ ហិកតា
- ថែរក្សា ឬកែលម្អសេវាប្រព័ន្ធអេកូឡូស៊ី
- ការអភិវឌ្ឍន៍ដែលធន់នឹងអាកាសធាតុ នៅតាមសហគមន៍ដាំស្រូវនៅជុំវិញបឹងទន្លេសាប។

## លទ្ធផលរយៈពេលវែង

- ផលិតភាព និងគុណភាពនៃផលិតផលកសិកម្មរបស់អ្នកប្រកបរបរតូចតាចត្រូវបានបង្កើនឡើង។
- សន្តិសុខស្បៀង ភាពធន់នៃនឹងសេដ្ឋកិច្ចគ្រួសារ មានប្រាក់ចំណូល និងអាហារូបត្ថម្ភល្អ។
- ការសឹករេចរឹលដី និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ត្រូវបានកាត់បន្ថយ ចំណែកជីវចម្រុះ និងប្រព័ន្ធអេកូឡូស៊ីមានលំនឹងល្អ។


**Co-implemented by:**

**With the technical support of:**

Food and Agriculture Organization of the United Nations

**Funded by:**

gef